# សិលាចារឹកភ្នំបារៀង (K.1562) ខេត្តកំពង់ធំ

ក្រុមប្រាសាទភ្នំបារៀង ជាបុរាណដ្ឋានដ៏មានសារៈសំខាន់មួយកន្លែង ដែលមានទីតាំងស្ថិតនៅឃុំគោល ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ហ៊ុមព័ទ្ធជុំវិញដោយភូមិចំនួនបួន រួមមាន ភូមិកគោ ភូមិកំពង់ផ្កា ភូមិបាក់ស្រី និងភូមិចារ ហើយស្ថិតនៅខាងត្បូងស្ទឹងសែនចម្ងាយប្រមាណ ១ គ.ម. និងខាងកើតតំបន់ប្រាសាទសំបូរព្រៃគុកប្រមាណ ២០គ.ម.។ បុរាណដ្ឋាននេះ ប្រមូលផ្តុំដោយប្រាង្គប្រាសាទជាច្រើន តាំងពីចង្កេះភ្នំរហូតដល់កំពូលភ្នំ តែប្រាសាទភាគច្រើនបានបាក់បែកនៅសល់តែគ្រឹះប៉ុណ្ណោះ លើកលែងតែប្រាង្គមួយនៅខាងកើតដែលនៅសល់ជញ្ជាំងឥដ្ឋមួយចំហៀងដែលរុំព័ទ្ធដោយដើមឈើធំមួយដើម។ ការហៅបុរាណដ្ឋាននេះថា "**បារៀង**" គឺទំនងក្លាយមកពីពាក្យដើមថា "**ព្រះរៀង**" ដែលអាចសំដៅលើប្រាង្គប្រាសាទដែលសង់ជាថ្នាក់ៗរៀងគ្នាចាប់ពីចង្កេះភ្នំរហូតដល់កំពូលភ្នំ ឬអាចហៅសំដៅដល់រូបថ្មគោលចំនួន ៤ ដើម ដែលមានចម្លាក់ទេពទាំងសងខាងតម្កល់នៅក្នុងខ្ទមយាយទេពត្រង់ជួរគ្នាពីជើងទៅត្បូង ដែលមើលទៅហាក់ដូចជារូបព្រះកំពុងស្ថិតនៅរៀងគ្នាដូច្នោះដែរ។ នៅត្រង់ផ្នែកកំពូលនៃភ្នំបារៀង មាននៅសល់មេទ្វារចារឹកចំនួន ១ ផ្ទាំង ហើយសព្វថ្ងៃកំពុងដាក់តម្កល់នៅរោងប្រក់ព្រះពុទ្ធរូបសម័យថ្មី។ តើសិលាចារឹកនេះមានខ្លឹមសារ និងអត្ថន័យដូចម្ដេចខ្លះ?

សិលាចារឹកនេះ ជាប្រភេទចារឹកអក្សរនៅលើមេទ្វារធ្វើអំពីថ្មភក់ ចំនួន ១ ជ្រុង មានចំនួន ៣៦ បន្ទាត់ ជាភាសាសំស្ក្រឹត ហើយបើគិតជាស្លោកស្មើនឹង ១៨ ស្លោក។ ក្នុងចំណោមអក្សរចារឹកទាំងនេះ មានរលុបអក្សរតិចតួចប៉ុណ្ណោះ ហើយបើតាមខ្លឹមសារដែលរៀបរាប់រំឭកអំពីព្រះបាទស្រីជយវម៌្ម (ទី៣) និងព្រះបាទស្រីឥន្រ្ទវម៌្ម (ទី១) និងរូបរាងអក្សរ យើងអាចសន្និដ្ឋានថា សិលាចារឹកនេះចារឹកឡើងនៅរវាងចុងស.វ.ទី៩ ដល់ពាក់កណ្ដាលស.វ.ទី១០។ ទិន្នន័យនេះ អាចឱ្យយើងដឹងថា ទោះបីជាប្រាង្គប្រាសាទភាគច្រើនកសាងឡើងនៅរចនាបថព្រៃក្មេង នារជ្ជកាលព្រះបាទស្រីភវវម៌្ម (ទី២) ឬព្រះបាទស្រីជយវម៌្ម (ទី១) (ស.វ.ទី៧) ក៏ដោយ បុរាណដ្ឋានត្រូវបានព្រះរាជា ឬព្រាហ្មណ៍បានជួសជុលសិវលិង្គជាថ្មីឡើងវិញ នាចុងស.វ.ទី៩ ឬស.វ.ទី១០។

ចំពោះខ្លឹមសារជារួមរបស់សិលាចារឹកនេះ ស្លោកទី១ កំណាព្យពណ៌នាអំពីពាក្យនមស្ការដល់ត្រិទេព ឬឬត្រិមូតិ៌ទេពនៃព្រហ្មញ្ញសាសនា ពោល គឺព្រះសិវ ព្រះវិស្ណុ និងព្រះព្រហ្ម។ ស្លោកទី២ ពណ៌នាអំពីព្រះបាទស្រីជយវម៌្ម (ទី៣) ដែលជាស្ដេចនៃដែនកម្ពុជទេស។ ស្លោកទី៣ រៀបរាប់អំពីព្រាហ្មណ៍ម្នាក់ឈ្មោះ "**វិស្ណុ**" ជារាជមន្ត្រីរបស់ព្រះបាទស្រីជយវម៌្ម (ទី៣) ដែលជាអ្នកមាន

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់

*ចំណេះដឹងជ្រៅជ្រះខាងគម្ពីរត្រៃវេទ និងទទួលបានការតែងតាំងអំពីស្តេចផែនដី។ ស្លោកទី៤ កំណាព្យចាប់ផ្តើមរៀបរាប់អំពីគុណសម្បត្តិ និងលក្ខណៈសម្បត្តិកិរិយារបស់ព្រាហ្មណ៍នេះ ដែលមានឈ្មោះថា "**ព្រហ្មាណី**"។ មកដល់ស្លោកទី៥ ពណ៌នាអំពីបុត្រារបស់គាត់ ប៉ុន្តែអក្សររលុបបាត់ឈ្មោះ និងកិរិយារបស់គាត់មាននាមថា "**ក្សេត្រជ្ញ**"។ ស្លោកទី៦ ពណ៌នាអំពីយោគីនម្នាក់ជា "**រាជសទ្គុរុ**" (គ្រូមានមហាចិត្តសត្បុរុស) ដែលមាននាមថា "**វិន្ទុសិវ**" និងស្លោកបន្ទាប់ (ទី៧) រៀបរាប់អំពីគុណសម្បត្តិ និងចំណេះដឹងរបស់រាជសទ្គុរុនេះ។ មកដល់ស្លោកទី៨ ពណ៌នាអំពីគុណសម្បត្តិកិរិយារបស់ស្រីនិវាស និងស្លោកទី៩ ពណ៌នាអំពីគុណសម្បត្តិរបស់អគ្រមហេសីរបស់ព្រះបាទស្រីន្ទ្រវម្ម័ (ទី១) ហើយស្លោកទី១០ ពណ៌នាអំពីបុត្រីច្បងរបស់ព្រះអង្គដែលមានព្រះនាមថា "មាធវី"។ មកដល់ស្លោកទី១១ ដល់ទី១៥ កំណាព្យចាប់ផ្តើមពណ៌នាអំពីគុណសម្បត្តិ និងចំណេះដឹងរបស់ព្រាហ្មណ៍ឈ្មោះ "សិវាចារ្យ" និងការធ្វើកិច្ចប្រតិបត្តិក្នុងពិធីសាសនារបស់លោក។ ស្លោកទី១៦ ដល់ទី១៨ ពណ៌អំពីការជួសជុលព្រះសិវលិង្គ ការបូជា និងការបរិច្ចាគទាន ថ្វាយដល់ទេវស្ថាន។*

## អត្ថបទចារឹក និងសេចក្តីប្រែ

១.   នមត្ក្តិវាយ យទ្ធាម   វេធោមាធវគម្ភុភិះ
    កុទ្ធមិទ្ធមយធ្យេយ   មធិគន្ទិយតាត្មភិះ។

**ប្រែថា៖** *សូមនមស្ការចំពោះ**ព្រះគិរ** (សិវ)! រស្មីដ៏រុងរឿងឯណាដែលបរិសុទ្ធ ភ្លឺស្វាង និងជាទីតាំងនៃ**ព្រះវេធស** (ព្រះព្រហ្ម), **ព្រះមាធវ** ព្រះវិស្ណុ, និង **ព្រះគម្ភុ** (ព្រះសិវ) រស្មីនោះ គឺជាទីតាំងនៃព្រះធម៌ដ៏បរិសុទ្ធដែលព្រះយោគីទាំងឡាយតែងតែតាំងចិត្តរំឭកដល់ជានិច្ច។*

២.   ......ត តាកោន្ទ្រ   រាជ្យក្រុក្តភូធីត្វរះ
    [អាសីតត្រិជ]យវម៌្មតិ   កាម្ពុជេន្ទ្រាវតង្សកះ។

**ប្រែថា៖** *ក្នុងមហាសករាជ.......* មានព្រះរាជាមួយព្រះអង្គ *ទ្រង់ជា **ភូភូទីត្វរ** (ស្តេចផែនដី)*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

*ដែលបានសោយរាជ្យជាអធិបតីលើក្សត្រទាំងឡាយ ទ្រង់មានព្រះនាមថា "**ត្រីជយវម៌្ម**" ដែលជា **កម្ពុជេន្ទ្រាវតង្សក** (គឺព្រះមហាក្សត្រកម្ពុជាដែលជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុត ដូចជារាជមកុដដែលស្ថិតនៅលើព្រះសិរស្តេចទាំងឡាយ)។*

៣. ………ត្រិវេទជ្ញោ ព្រាហ្មណោវិឞ្ណុនាមកូត

……………តូត្រេ និយុក្តោធរណីភុជា។

ប្រែថា៖ *……….. (មាន) ព្រាហ្មណ៍ម្នាក់ជា **ត្រិវេទជ្ញ** ដែលចេះដឹងនូវព្រះត្រៃវេទ មាននាមថា **វិឞ្ណុ** (វិឞ្ណុនាមកូត) ត្រូវបានតែងតាំងដោយ **ព្រះធរណីភុជ** (ព្រះរាជា) ឱ្យទទួលបន្ទុកក្នុងតំណែងជា………………។*

៤. …………………អាសី តស្យ កាយ៌្យសុសន្ធតា

………………………និ ប្រែហ្មណីនាម ធារិណី។

ប្រែថា៖ *….. (មានស្ត្រីម្នាក់) ជាភរិយាដ៏ជាទីគាប់ចិត្តរបស់លោក (មន្ត្រី ឬព្រាហ្មណ៍នោះ)។ នាងជាស្ត្រីដែលមានសីលធម៌ដ៏ល្អនោះ មាននាមថា **ប្រែហ្មណី** ដែល……………………។*

៥. ……………………នាម្នា សុតាសៅន្ទយ៌្យរូបិណី

……………………[អា]សី ត្តៅត្រិជ្ញាខ្យស្យនិធេះ។

ប្រែថា៖ *មានបុត្រីម្នាក់នាម…………… ដែលមានរូបរាងដ៏ស្រស់ស្អាត…………គឺជាភរិយារបស់លោក **ក្សេត្រជ្ញ** ដែលជាបុគ្គលប្រៀបដូចជាកំណប់នៃគុណសម្បត្តិ។*

៦. …………………យោគី កាវ៌្វិន្ទុតិវាហ្វយះ

…………………ស គោចពោរាជសទ្គុរុះ។

ប្រែថា៖ *…… មានព្រះយោគីម្នាក់ ហើយក៏ជាកវីម្នាក់ផងនាមថា **វិន្ទុតិវ** …………….លោកគឺជាទីប្រឹក្សា និងជា **ព្រះរាជសទ្គុរុ** (ព្រះគ្រូដ៏ប្រសើររបស់ព្រះរាជា)។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

៧. ....................ភល　　　　ក្យ្វណាំ បរមោគុរុះ
................តាជៀ　　　　រច្ចិ៍តោភជជីមធាះ។

ប្រែថា៖ ......... *លោកគឺជា* ***ព្រះបរមគ្រូ*** *(ព្រះគ្រូដ៏ខ្ពង់ខ្ពស់) ក្នុងចំណោមពួកគ្រូទាំងឡាយ* ............. *លោកត្រូវបានគោរពបូជាដោយព្រះរាជាទាំងឡាយ និងពួកអ្នកប្រាជ្ញាទាំងឡាយ។*

៨. ..............ឆ្គាខ្យា　　　　ត្រីនិវាសស្យជីមតះ
គា..........ត្រាភត្ម　　　　ជាគេ ភាគវត្យុះ។

ប្រែថា៖ .....*មានស្ត្រីម្នាក់នាមថា*.......... *ដែលជាភរិយារបស់លោក* ***ត្រីនិវាស*** *ជាអ្នកមានប្រាជ្ញា* ............*នាងជាស្ត្រីដែលមានកិច្ចប្រតិបត្តយ៉ាងល្អប្រពៃចំពោះស្វាមី ទោះបីជាស្វាមីបានចែកស្ថានទៅហើយក៏ដោយ ហើយនាងក៏ជាស្ត្រីដែលមានសេចក្ដីជ្រះថ្លាក្នុង* ***ព្រះភាគវតី*** *ផងដែរ។*

៩. ............មហាទេវី　　　　ត្រីមតិត្រីន្ទ្រវម៌្មណះ
..............សទ្វ៌គុណិនី　　　　ភជកោគោបការិណី។

ប្រែថា៖ .....*ព្រះមហាទេវី (ព្រះមហេសី) ដ៏មានសិរីរបស់ព្រះបាទ* ***ត្រីន្ទ្រវម៌្ម*** *ឬ* ***ត្រីឥន្ទ្រវម៌្ម*** ...............*ព្រះនាងជាស្ត្រីប្រកបដោយគុណសម្បត្តិទាំងពួង និងជា* ***រាជោបការិណី*** *គឺនារីដែលធ្វើឱ្យមានគុណូបការៈដល់ព្រះរាជា។*

១០. .............ឈាជ្យេម្ពា　　　　មាធវី ធាម ធារិណី
..............ភិកាយ៌្យា　　　　ភជចាមរធារិណះ។

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

**ប្រែថា៖** *(ព្រះនាង) មានបុត្រីច្បង (ជេដ្ឋា) មួយព្រះអង្គ.......... នាមថា **មាធវី** .......... នាង គឺជាកិរិយារបស់មន្ត្រីម្នាក់ ដែលមានតួនាទីជា **រាជចាមរធារិន** គឺអ្នកកាន់ផ្លិតរោមសត្វចាមរ ថ្វាយព្រះរាជា។*

១១. ..............អាចាយ៌្យ គិរាចាយ៌្យ ឥតិវិតះ

...............យាគីស បិឍ្យគោចត...និជិះ។

**ប្រែថា៖** ..........*មានព្រះអាចាយ៌្យម្នាក់ដែលគេតែងតែហៅថា **គិរាចាយ៌្យ** ...............លោក គឺជាកំណប់នៃចំណេះដឹង និងសេចក្តីស្ងប់................។*

១២. ..........រិត..កាយ៌្យ ....ចាណការតដ្វលមិ

................និវ៌្វណ្ដោ ..............ឈ្យាមត។

**ប្រែថា៖** ............*កិច្ចការទាំងឡាយដែលត្រូវធ្វើ........ ការលះបង់នូវចំណង់ទាំងពួង.......។*

១៣. .................កាម្តមុ តៃវ្យាការណាជិមុ

.......មតីតន្តីព្រ្វោះ យស្យ ឧរ្វបសន្តតិះ។

**ប្រែថា៖** *(លោកជាអ្នកជំនាញ) ............ក្នុងវិជ្ជាដ៏ជ្រៅជ្រះមានដូចជា វេយ្យាករណ៍ និងលទ្ធិគិរជាដើម............ លោក គឺជាអ្នកដែលឈ្នះលើរាល់ឧបសគ្គ និងការយល់ច្រឡំទាំងឡាយ។*

១៤. ព្រតវិទ្យាចំ តិលៃក មាងសោក្យន្នជាជ្វិតិ

យតិចការតបស្តិ្រំ កាម្ពុសក្ត៌សិស្វក្ឈ្យយា។

**ប្រែថា៖** *លោកមានការតាំងចិត្តរឹងមាំតែមួយគត់លើការសិក្សា និងព្រតប្រតិបត្តិ។ លោកបានធ្វើតបៈយ៉ាងខ្លាំងក្លា ដោយមានបំណងនឹងបង្កើតនូវអ្វីដែលជាប្រយោជន៍ដល់**ដែនដីកម្ពុជា** (កម្ពុសក្ត៌)។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

១៥. តបះ ក្សាន្តិបម្ភាភិះ     កុរុភិះ សុតបស្វិភិះ
មធ្យស្ថោគ្និតបះក្សា     ជ្យោម្តជិក្សុប្មតោជិតមិ។

ប្រែថា៖ *ក្នុងអំឡុងពេលដែលកំពុងធ្វើតបៈ មានព្រះគ្រូដែលជា* ***តបស្វិន*** *៨ ព្រះអង្គ បាននៅហែរហម ហើយលោកបានស្ថិតនៅចំកណ្តាលនៃព្រះភ្លើងតបៈនោះ ដោយដែលកំពុងឆេះយ៉ាងសន្ធោសន្ធៅនៅជុំវិញខ្លួនក្នុងទិសទាំង ៨ ជាប្រចាំមិនដាច់។*

១៦. វជេជ្រុម សតាវីបុ     ...លិង្គមេត្វរមិ
សំស្ថាត្យ វិធិនា សោបិ     តស្យ បូជាមការយត៍។

ប្រែថា៖ *.....បន្ទាប់ពីបានធ្វើការជួសជុលនូវ* ***ព្រះឦត្វរលិង្គ*** (ព្រះគិវលិង្គ) *តាមក្បួនវិធីយ៉ាងត្រឹមត្រូវរួចមក លោកក៏បានចាត់ចែងឱ្យមានការបូជាចំពោះព្រះអង្គ។*

១៧. ភក្តិតោមហិមក្សេត្រ     ធាសាធាស្យាជិកង្គជមិ
ជិក្សុ....វិជិភិល័រ     មស្នង្គេដ ប្រុតល្បិតមិ។

ប្រែថា៖ *លោកបានបរិច្ចាគនូវទ្រព្យធនទាំងឡាយរួមមាន គោ ក្របី ដីស្រែ និងខ្ញុំបម្រើប្រុសស្រីជាអាទ៍.....គ្រឿងសក្ការបូជាទាំងឡាយត្រូវបានរៀបចំឡើងយ៉ាងឱឡារិក។*

KHMER CIVILIZATION

១៨. ............................     ...មតង្គេដ យាតជមិ
............................     ............................។

ប្រែថា៖ *..........ដោយសេចក្តីព្យាយាមរបស់លោក....។*

សរុបជារួមមក សិលាចារឹករកឃើញនៅប្រាសាទភ្នំបារៀង គឺជាសក្ខីកម្មយ៉ាងសំខាន់ក្នុងការស្វែងយល់ពីតំបន់បុរាណដ្ឋានភ្នំបារៀង។ តាមរយៈខ្លឹមសារទាំង ១៨ ស្លោកនៃសិលាចារឹកនេះ បានផ្តល់ទិន្នន័យប្រវត្តិសាស្ត្រសំខាន់ៗចំនួន ៣ គឺ ផ្នែកជំនឿ ផ្នែកប្រវត្តិសាស្ត្រនិងនយោបាយ និងផ្នែករចនាសម្ព័ន្ធសង្គម។ ផ្នែកជំនឿ គឺបានបង្ហាញពីការគោរពបូជាយ៉ាងខ្ជាប់ខ្ជួនចំពោះព្រហ្មញ្ញសាសនា តាមរយៈពាក្យនមស្ការដល់ត្រីទេព (ព្រះសិវ ព្រះវិស្ណុ និងព្រះព្រហ្ម) ព្រមទាំងការរៀបរាប់អំពីការធ្វើតបៈយ៉ាងមុតមាំ និងការជួសជុលព្រះសិវលិង្គថ្វាយទេវស្ថាន។ ចំណែកផ្នែកប្រវត្តិសាស្ត្រនិងនយោបាយ គឺរៀបរាប់អំពីព្រះនាមព្រះមហាក្សត្រដែលបានសោយរាជ្យ និងគ្រប់គ្រងដែនដីកម្ពុជទេស គឺព្រះបាទស្រីជយវម្ម (ទី៣) និងព្រះបាទស្រីឥន្ទ្រវម្ម (ទី១)។ ដោយឡែក ផ្នែករចនាសម្ព័ន្ធសង្គម គឺឆ្លុះបញ្ចាំងអំពីតួនាទី និងគុណសម្បត្តិរបស់ពួកព្រាហ្មណ៍ មន្ត្រីរាជការ ព្រះរាជគ្រូ (ដូចជាព្រាហ្មណ៍ វិស្ណុ, វិន្ទុសិវ និងសិវាចារ្យ) ព្រមទាំងសីលធម៌ដ៏ល្អប្រពៃនៃស្ត្រីខ្មែរបុរាណដែលជាភរិយា និងបុត្រីរបស់វណ្ណៈខ្ពង់ខ្ពស់នាជំនាន់នោះ។ ម្យ៉ាងវិញទៀត ទោះបីជាប្រាង្គប្រាសាទភាគច្រើននៅភ្នំបារៀងដែលបាក់បែកទាំងនោះសាងឡើងនៅស.វ.ទី៧ ក៏ដោយការលេចវត្តមាននៃសិលាចារឹកនេះបានបញ្ជាក់យ៉ាងច្បាស់ថា បុរាណដ្ឋានមួយនេះត្រូវបានព្រះរាជា ឬពួកព្រាហ្មណ៍ បន្តធ្វើការជួសជុល និងរៀបចំពិធីបូជាជាថ្មីឡើងវិញយ៉ាងឱឡារិក នៅចន្លោះចុងសតវត្សទី៩ ដល់ពាក់កណ្តាលសតវត្សទី១០ ដែលជាភស្តុតាងបង្ហាញពីការបន្តវេននៃកិច្ចប្រតិបត្តិសាសនាយ៉ាងរស់រវើកក្នុងសង្គមខ្មែរបុរាណ។

.

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ១៖ ប្រាសាទភ្នំបារៀង (ប្រភព៖ ម៉ង់ វ៉ាលី)



រូបលេខ២៖ មេឡាចារឹកប្រាសាទភ្នំបារៀង (ប្រភព៖ ម៉ង់ វ៉ាលី)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ៣ៈ សំណៅផ្តិតសិលាចារឹកប្រាសាទភ្នំបារៀង (ក្រដាសទី១ ផ្នែកខាងលើ)
(ផ្តិតដោយៈ កំ វណ្ណារ៉ា, ម៉ង់ រ៉ាលី, កុំ រតនៈពិសិដ្ឋ)

អត្ថបទដោយៈ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ២៨៖ សំណៅផ្តិតសិលាចារឹកប្រាសាទភ្នំបារៀង (ក្រដាសទី២ ផ្នែកខាងក្រោម)
(ផ្តិតដោយ៖ កំ វណ្ណារ៉ា, ម៉ង់ រ៉ាលី, កុំ រតនៈពិសិដ្ឋ)

អរិយធម៌ខ្មែរ KHMER CIVILIZATION